ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខៈ ១៩៧ (ជ.ក)

រាជធានីភ្នំពេញ. ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ ២០០៨

# ប្រកាស

## ស្តីពី

## តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធ របស់សាលាមធ្យមវិចិត្រសិល្បៈ

## រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើត ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញ អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- តាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១.-**

សាលាមធ្យមវិចិត្រសិល្បៈ ជាអង្គភាពស្ថិតក្រោមឱវាទ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានសមត្ថភាពក្នុងការដឹកនាំ គ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្សលើវិស័យសិល្បៈវប្បធម៌របស់ក្រសួង។

**ប្រការ ២.-**

សាលាមធ្យមវិចិត្រសិល្បៈ មានភារកិច្ចដូចតទៅ :

- ជ្រើសរើសសិស្សតាមឧបនិស្ស័យអោយចូលសិក្សា និងប្រឡងបញ្ចប់ដោយផ្តល់នូវសញ្ញាប័ត្រ សិល្បៈ និង ស្នាតកប័ត្រសិល្បៈ

- បណ្តុះបណ្តាលធនធានមនុស្សចាប់តាំងពីកម្រិតបឋមដល់មធ្យម ដើម្បីអោយក្លាយជាអ្នកជំនាញសិល្បៈទាំងទ្រឹស្តី ទាំងការអនុវត្តន៍ និងបង្កើតថ្មីតាមការចាំបាច់របស់សង្គម
- បំពាក់បំប៉នមន្ត្រីជំនាញ និង សិល្បករអោយក្លាយជាគ្រូបង្ហាត់ដែលមានគុណសម្បត្តិសិល្បៈ និងវិជ្ជាជីវៈពេញលេញ
- ស្រាវជ្រាវចងក្រងកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនទុកជាឯកសារបច្ចេកទេសសិល្បៈ
- សម្របសម្រួលកម្មវិធីសិក្សាជាមួយ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងសហការជាមួយអង្គការជាតិ និងអន្តរជាតិលើមូលដ្ឋានការងារបណ្តុះបណ្តាល និងស្រាវជ្រាវបច្ចេកទេសសិល្បៈ ដើម្បីធ្វើការអោយកាន់តែប្រសើរឡើងនូវការអប់រំសិល្បៈ
- ធ្វើរបាយការណ៍លើសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តន៏ភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន
- សាលាមធ្យមវិចិត្រសិល្បៈមានភារកិច្ចសហការជាមួយសាលាផ្សេងៗ ទាំងក្នុង និងក្រៅប្រទេស លើផ្នែកបណ្តុះបណ្តាល វិស័យសិល្បៈវប្បធម៌ដើម្បីផ្លាស់ប្តូរបទពិសោធន៏ ។

ប្រការ ៣.-

សាលាមធ្យមវិចិត្រសិល្បៈ ដឹកនាំដោយនាយកសាលាមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងនាយករងមួយចំនួនមានឋានៈស្មើអនុប្រធាននាយកដ្ឋានជាជំនួយការតាមការចាំបាច់។

ប្រការ ៤.-

សាលាមធ្យមវិចិត្រសិល្បៈ មានរចនាសម្ព័ន្ធដូចតទៅ :

ក.<u>ការិយាល័យ</u>

១-ការិយាល័យ រដ្ឋបាល បុគ្គលិក

២-ការិយាល័យសិក្សា

៣-ការិយាល័យ ផែនការគណនេយ្យ និងហិរញ្ញវត្ថុ

៤-ការិយាល័យ បណ្ណាល័យ

ខ.<u>សាលាសិល្បៈ</u>

១-សាលារបាំ

២-សាលាល្ខោន

៣-សាលាតូរ្យតន្ត្រី

៤-សាលាសៀក

៥-សាលាសិល្បៈសូនរូប

ក្នុងករណីចាំបាច់ សាលាមធ្យមវិចិត្រសិល្បៈ អាចបង្កើតសាលាឯកទេសសិល្បៈផ្សេងៗទៅតាមការរីកចំរើនរបស់សង្គមជាតិ ។

ការិយាល័យ និង សាលានីមួយៗ មានប្រធានមួយរូប ទទួលខុសត្រូវរួម និង អនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**ប្រការ ៥.-**

ភារកិច្ចរបស់ការិយាល័យ និង សាលានីមួយៗមានដូចតទៅ :

១.<u>ការិយាល័យរដ្ឋបាល បុគ្គលិក</u>

- គ្រប់គ្រងឯកសារ លិខិតចេញ លិខិតចូលគ្រប់ប្រភេទ
- គ្រប់គ្រងសំរបសំរួលការងាររដ្ឋបាល ផែនការស្ថិតិ និង បូកសរុប
- គ្រប់គ្រងការងារបុគ្គលិក ការងារក្របខណ្ឌ និង បណ្តុះបណ្តាល
- គ្រប់គ្រងថែរក្សាទុកដាក់ឯកសារគ្រប់ប្រភេទរបស់សាលាមធ្យមវិចិត្រសិល្បៈអោយមានរបៀប និង សណ្តាប់ធ្នាប់ល្អ
- គ្រប់គ្រងសំភារៈ និង បរិក្ខាររបស់សាលា
- គ្រប់គ្រងប្រព័ន្ធពត៌មានវិទ្យា
- ទទួលអនុវត្តន៍ភារកិច្ចផ្សេងៗទៀត ដែលនាយកសាលាប្រគល់ជូន
- អនុវត្តន៍របបរាយការណ៍ទៀងទាត់ជូននាយកសាលាមធ្យមវិចិត្រសិល្បៈ ។

២.<u>ការិយាល័យសិក្សា</u>

- ការិយាល័យសិក្សាជាលេខាធិការដ្ឋានកណ្តាលមួយ នៃសាលាមធ្យមវិចិត្រសិល្បៈមានតួនាទីផ្សព្វផ្សាយ និងបង្កើតកម្មវិធីសិក្សាដើម្បីអោយសាលាមធ្យមវិចិត្រសិល្បៈមានដំណើរការ ព្រមទាំងប្រមូលផ្តុំឯកសារដែលពាក់ព័ន្ធ និងការសិក្សារបស់សិស្ស
- រៀបរៀង និងត្រួតពិនិត្យកម្មវិធីសិក្សារបស់សិស្ស
- គ្រប់គ្រងស្ថិតិរបស់សិស្ស
- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័នដែលពាក់ព័ន្ធ
- ទំនាក់ទំនងជាមួយមាតាបិតាសិស្ស
- បញ្ជាក់លិខិតស្នាមផ្សេងៗ
- រៀបចំកាលវិភាគរបស់សិស្ស
- ពង្រឹងវិន័យរបស់សិស្ស និង គ្រូ
- ប្រមូល និងបូកសរុបពិន្ទុរបស់សិស្ស ប្រចាំខែ ប្រចាំឆមាស និង ប្រចាំឆ្នាំ

- តាមដាន និងទទួលខុសត្រូវ បទបញ្ជាផ្ទៃក្នុងរបស់សិស្ស
- ធ្វើកម្រងកម្មវិធីសិក្សាតាមសាលាដើម្បីទុកជាឯកសារ
- រៀបចំសណ្តាប់ធ្នាប់ផ្នែកសិក្សារបស់សិស្ស
- រៀបចំការប្រឡងយកសញ្ញាប័ត្រ ប្រចាំឆ្នាំនៃសាលាមធ្យមវិចិត្រសិល្បៈ ។

**៣.ការិយាល័យផែនការ គណនេយ្យ និង ហិរញ្ញវត្ថុ**

- រៀបចំឯកសារផែនការ និង លើកគំរោងផ្សេងៗ ប្រចាំឆ្នាំ
- គ្រប់គ្រងគណនេយ្យ និង ហិរញ្ញវត្ថុ ប្រចាំឆ្នាំរបស់សាលាមធ្យមវិចិត្រសិល្បៈ
- តាមដានពិនិត្យប្រាក់ និង ទូទាត់ចំណូលចំណាយ
- ប្រមូលចំណូលផ្សេងៗរបស់សាលាមធ្យមវិចិត្រសិល្បៈ
- បើកប្រាក់ចំណាយ
- រៀបចំគំរោងចំណាយផ្សេងៗ ប្រចាំខែ ឆ្នាំ របស់សាលាមធ្យមវិចិត្រសិល្បៈ
- ធ្វើរបាយការណ៍
- ចុះបញ្ជីកត់ត្រា រក្សាទ្រព្យសម្បត្តិរដ្ឋ ក៏ដូចជាសម្បត្តិសាលាមធ្យមវិចិត្រសិល្បៈ... ។

**៤.ការិយាល័យបណ្ណាល័យ**

- អប់រំសិស្សដោយផ្អែកលើឧបនិស្ស័យ ចំណង់ចំណូលចិត្ត និង ការប៉ុនប្រសប់ សិស្សអាចទទួល
- យកបាននូវចំណេះដឹងផ្នែកសិល្បៈ វប្បធម៌ អរិយធម៌ ប្រពៃណីខ្មែរតាមរយៈការអាន រហូត ឈានដល់ការស្រាវជ្រាវបែបវិទ្យាសាស្ត្រភាវូបនីយកម្មឆ្ពោះប្រឌិតទាន់សម័យ
- រៀបចំកម្មវិធីបណ្តុះបណ្តាលសិស្ស អោយស្រឡាញ់ការអានប្រកបដោយសីលធម៌
- រៀបចំការផ្សព្វផ្សាយ អប់រំអោយសិស្សបានស្គាល់ យល់ដឹងពីប្រពៃណី ទំនៀមទំលាប់វប្បធម៌ អរិយធម៌ ជាតិសាសន៍របស់ខ្លួន
- ស្រាវជ្រាវ ចងក្រងឯកសារសាលាសិល្បៈទាំង ៥ ដើម្បីរក្សាអត្តសញ្ញាណជាតិអោយរឹងមាំ និង គង់វង្ស
- មានគំរោងផ្តល់រង្វាន់ដល់សិស្ស និងបេក្ខជនដែលនិយមការអានច្រើនជាងគេ ។

**៥.សាលារបាំ**

- សាលារបាំមានភារកិច្ចបណ្តុះបណ្តាលធនធានមនុស្ស លើមុខវិជ្ជារបាំមាន :
  - + ផ្នែករបាំបុរាណ
  - + ផ្នែករបាំប្រពៃណី
  - + ផ្នែកល្ខោនខោល
- ការសិក្សាស្រាវជ្រាវ និងថែរក្សាអត្តសញ្ញាណជាតិ ហើយនិង អភិវឌ្ឍន៍សិល្បៈរបាំ

- ផ្សព្វផ្សាយចំណេះដឹងសិល្បៈវប្បធម៌ ដល់យុវជន និង សាធារណជន
- បណ្តុះបណ្តាលអប់រំសិល្បករអាជីព និង ក្រុមខណ្ឌ និង ធ្វើវិក្រឹត្យការ ឯកទេសរបាំតាមទម្រង់ក្បួនខ្នាតច្បាស់លាស់
- បណ្តុះបណ្តាលសិល្បករ កំរិតភូមិសិក្សាទី១ ( សញ្ញាប័ត្រសិល្បៈ ) និង ភូមិសិក្សាទី២ ( ស្នាតកប័ត្រសិល្បៈ ) ឯកទេសសំដែង ។

**៦.សាលាល្ខោន**

- សាលាល្ខោនមានភារកិច្ច បណ្តុះបណ្តាលសិស្សលើវិជ្ជាសិល្បៈល្ខោន

ចំនួនបីទម្រង់គឺ : ១-ល្ខោន និយាយ

២-ល្ខោន យីកេ

៣-ល្ខោន បាសាក់

- ស្រាវជ្រាវ និង ថែរក្សាអត្តសញ្ញាណជាតិ ហើយនិង អភិវឌ្ឍន៍សិល្បៈល្ខោន
- ផ្សព្វផ្សាយ ចំណេះដឹងសិល្បៈវប្បធម៌ ដល់យុវជន និង សាធារណជន
- បណ្តុះបណ្តាលសិល្បករអាជីព និង ក្រុមខណ្ឌ វិក្រឹត្យការ ឯកទេសល្ខោន តាមទ្រង់ទ្រាយក្បួនខ្នាតច្បាស់លាស់
- បណ្តុះបណ្តាលសិល្បករកំរិត សញ្ញាប័ត្រសិល្បៈ និង ស្នាតកប័ត្រសិល្បៈ ( ឯកទេសសំដែង ) ។

**៧.សាលាតូរ្យតន្ត្រី**

- បណ្តុះបណ្តាលសិស្ស ផ្នែកតូរ្យតន្ត្រី ផ្អែកលើមូលដ្ឋានគ្រឹះឯកទេសជំនាញតន្ត្រីបុរាណ និង តន្ត្រីសកលទាំង ២៤ ជំនាញរួមមាន :

| | | |
|---|---|---|
| ១-វីយូឡុង | ៩-ហ្វ្លីតា | ១៧-គងតូច |
| ២-វីយូឡា | ១០-ហ្គុត | ១៨-គងធំ |
| ៣-ព្យាណូ | ១១-ចំរៀងជាពូក | ១៩-ឃឹម |
| ៤-ក្លារីណែត | ១២-ចំរៀងបុរាណ | ២០-តះខេ |
| ៥-ត្រុំប៉ែត | ១៣-ទ្រអ៊ូ | ២១-ខ្លុយ |
| ៦-សាក់សូ | ១៤-ទ្រសោ | ២២-ស្រឡៃ |
| ៧-សែលឡូ | ១៥-រនាដឯក | ២៣-អាយៃ |
| ៨-កុងត្រឹបាស់ | ១៦-រនាដធុង | ២៤-ចាប៉ី |

- ស្រាវជ្រាវគ្រប់មូលដ្ឋានគ្រឹះ នៃផ្នែកតូរ្យតន្ត្រី
- ផ្សព្វផ្សាយចំណេះដឹងសិល្បៈវិទ្យាសាស្ត្រសង្គម វប្បធម៌ ដល់យុវជន និង សាធារណជន
- ថែរក្សាអត្តសញ្ញាណជាតិ និង អភិវឌ្ឍន៍

- សាលាតូរ្យតន្ត្រីមានភារកិច្ចបណ្តុះបណ្តាល និងវិក្រឹត្យការ ក្របខណ្ឌវិទ្យាសាស្ត្រ និង សិល្បៈ តាមជំនាញ និង ស្រាវជ្រាវវិទ្យាសាស្ត្រសិល្បៈតាមទ្រង់ទ្រាយក្បួនខ្នាត
- សាលាតូរ្យតន្ត្រីមានភារកិច្ចទទួលបណ្តុះបណ្តាលសិស្សក៏រិតបឋមសញ្ញាប័ត្រសិល្បៈ និងស្នាតក ប័ត្រសិល្បៈដែលមានឧបនិស្ស័យផ្នែកជំនាញតូរ្យតន្ត្រី ។

៨. <u>សាលាសៀក</u>

- បណ្តុះបណ្តាលសិស្សផ្នែកសៀក ផ្អែកលើមូលដ្ឋានគ្រឹះឯកទេសជំនាញរួមមាន :

១-ឯកទេសអាក្រូបាត

២-ឯកទេសលំនឹង

៣-ឯកទេសត្រេះ

៤-ឯកទេសស៊ីណេស៊ីក

៥-ឯកទេសកំប្លែង

៦-ឯកទេសរហ័សកម្ម

៧-ឯកទេសផ្សាំងសត្វ

- ស្រាវជ្រាវគ្រប់មូលដ្ឋានគ្រឹះនៃផ្នែកសៀក
- ផ្សព្វផ្សាយចំណេះដឹងសិល្បៈវិទ្យាសាស្ត្រសង្គមវប្បធម៌ដល់យុវជន និង សាធារណជន
- ថែរក្សាអត្តសញ្ញាណជាតិ និង អភិវឌ្ឍន៍សិល្បៈសៀក
- សាលាសៀកមានភារកិច្ចបណ្តុះបណ្តាល និងវិក្រឹត្យការក្របខណ្ឌវិទ្យាសាស្ត្រ និងសិល្បៈតាម ជំនាញ និងស្រាវជ្រាវវិទ្យាសាស្ត្រតាមទ្រង់ទ្រាយក្បួនខ្នាត
- សាលាសៀកមានភារកិច្ច ទទួលបណ្តុះបណ្តាលសិស្សក៏រិតសញ្ញាប័ត្រសិល្បៈស្នាតកប័ត្រសិល្បៈ ដែលមានឧបនិស្ស័យផ្នែកជំនាញសៀក ។

៩. <u>សាលាសិល្បៈសូនរូប</u>

- បណ្តុះបណ្តាលសិស្ស ផ្នែកសិល្បៈសូនរូប ផ្អែកទៅលើមូលដ្ឋានគ្រឹះឯកទេសជំនាញសិល្បៈបុរាណ ខ្មែរទាំង ១០ ជំនាញរួមមាន :

| | |
|---|---|
| ១-សិល្បៈគំនូរវិចិត្រកម្ម | ៦-សិល្បៈចម្លាក់ប្រាក់ |
| ២-សិល្បៈគំនូរបុរាណ | ៧-សិល្បៈចម្លាក់ស្មិត |
| ៣-សិល្បៈគំនូរផ្សាយ | ៨-សិល្បៈចម្លាក់ពុម្ព |
| ៤-សិល្បៈលំអក្រណាត់ | ៩-សិល្បៈខ្មុកស្មាច់ |
| ៥-សិល្បៈចម្លាក់ឈើ | ១០-សិល្បៈកុលាលភាជន៍ |

- ស្រាវជ្រាវ គ្រប់មូលដ្ឋានគ្រឹះ នៃផ្នែកសិល្បៈសូនរូប

- ផ្សព្វផ្សាយ ចំណេះដឹងសិល្បៈវិទ្យាសាស្ត្រសង្គម វប្បធម៌ ដល់យុវជន និងសាធារណជន
- ថែរក្សាអត្តសញ្ញាណជាតិ និង អភិវឌ្ឍន៍ សិល្បៈសូនរូប
- បណ្តុះបណ្តាល និង វិក្រឹត្យការ ក្របខណ្ឌវិទ្យាសាស្ត្រ និង សិល្បៈតាមជំនាញ និង ស្រាវជ្រាវវិទ្យាសាស្ត្រសិល្បៈតាមទ្រង់ទ្រាយក្បួនខ្នាត
- បណ្តុះបណ្តាលសិស្សកំរិត សញ្ញាបត្រសិល្បៈ និង ស្នាតកបត្រសិល្បៈដែលមានឧបនិស្ស័យផ្នែកជំនាញសិល្បៈសូនរូប ។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អធិការនៃអធិការដ្ឋាន ប្រធាន នាយកដ្ឋានសវនកម្ម អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ អគ្គនាយកបេតិកភណ្ឌ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នាយកសាលាមធ្យមវិចិត្រសិល្បៈ ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត ក្រុង ទទួលបន្ទុកអនុវត្តន៍ប្រកាសនេះតាមភារកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

**វេង សិរីវឌ្ឍ**

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  " ដើម្បីជូនជ្រាបជាព័ត៌មាន "
- ដូចប្រការ ៧ " *ដើម្បីអនុវត្តន៍* "
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ...១៨៧/ប្រក......ចុះថ្ងៃទី.០៧.ខែកញ្ញា..ឆ្នាំ ២០០៨

អង្គការលេខរបស់សាលាមធ្យមវិចិត្រសិល្បៈ

